**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០០៧ សណាស

CAMBODIA
Kingdom of Wonder
feel the warmth

ថ្ងៃ សុក្រ ១១ កើត ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ មីនា ឆ្នាំ២០២១

# សេចក្តីណែនាំបន្ថែម

## ស្តីពី

## វិធានការបន្ទាន់ក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅទីស្តីការក្រសួងទេសចរណ៍

យោងតាមបទបញ្ជា និងប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាយប់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ និងស្របតាមវិធានការណែនាំនានារបស់ក្រសួងសុខាភិបាលក្នុងការបង្ការ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅទីស្តីការក្រសួងទេសចរណ៍ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិទាំងអស់** ដែលចេញ-ចូល មកបំពេញការងារ ក៏ដូចជាមានការកិច្ចមកទំនាក់ទំនងការងារនៅទីស្តីការក្រសួងទេសចរណ៍ ត្រូវចូលរួមអនុវត្តនូវវិធានការបន្ទាន់ ដូចខាងក្រោម៖

១. ផ្អាកជាបណ្តោះអាសន្នរយៈពេល ០១សប្តាហ៍ នូវបេសកកម្ម, កិច្ចប្រជុំ, សិក្ខាសាលា, វគ្គបណ្តុះបណ្តាល ឬការជួបជុំទាំងឡាយណា រហូតដល់មានបទបញ្ជាថ្មីរបស់រាជរដ្ឋាភិបាល។ អង្គភាពនីមួយៗអាចរៀបចំជំនួសមកវិញតាមប្រព័ន្ធអនឡាញ

២. អង្គភាពទាំងអស់ត្រូវរក្សាទុកមន្ត្រីយ៉ាងច្រើនបំផុតចំនួន ១០% ប៉ុណ្ណោះ ដែលមានភារកិច្ចចាំបាច់មកធ្វើការនៅទីស្តីការក្រសួងទេសចរណ៍ ក្រៅពីនោះ អនុញ្ញាតឱ្យមន្ត្រីរាជការធ្វើការនៅតាមផ្ទះតាមប្រព័ន្ធអនឡាញ

៣. ការប្រាស្រ័យទាក់ទងគ្នា គឺអាចធ្វើឡើងតាមប្រព័ន្ធទូរស័ព្ទ និងប្រព័ន្ធអនឡាញ (Online)

៤. រឹតបន្តឹងសន្តិសុខសណ្តាប់ធ្នាប់ក្នុងទីស្តីការក្រសួង ដោយត្រូវចេញ ឬចូលតាមច្រកខាងមុខក្រសួង និងតម្រូវឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចូលរួមក្នុងការពិនិត្យវាស់កម្តៅ លាងសំអាតដៃ និងស្កេន QR CODE ទប់ស្កាត់កូវីដ-១៩ (STOP COVID-19)

៥. ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការ "៣ការពារ និង ៣កុំ" តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

៦. ត្រូវអនុវត្ត "វិធានការគម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល" និងរក្សាអនាម័យជាប្រចាំ ដោយការពាក់ម៉ាស់ និងការអនុវត្តអនាម័យដៃស្អាតជានិច្ច ដោយត្រូវលាងសម្អាតដៃនឹងសាប៊ូ ទឹកអាល់កុល ឬទឹកជេល។

៧. ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ប្រសិនបើសង្ស័យថា មានការប៉ះពាល់អ្នកជំងឺកូវីដ-១៩ ឬមានរោគសញ្ញាសង្ស័យជំងឺកូវីដ-១៩ឬមានជំងឺផ្តាសាយដែលសង្ស័យ ត្រូវចូលរួមធ្វើតេស្តវិភាគរកវីរុសកូវីដ-១៩ និងត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកពីគេភ្លាមៗ។

៨. ត្រូវចូលរួមរាយការណ៍ ឬប្រសិនបើមានសំណួរ សូមហៅទៅលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥។

ទទួលបានសេចក្តីណែនាំនេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងទេសចរណ៍ទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារខាងលើ ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រី

ថោង ខុន